រាជបណ្ឌិត្យសភាកម្ពុជា

មុខវិជ្ជា៖ វិធីសាស្ត្រសរសេរនិក្ខេបបទ

កិច្ចការស្រាវជ្រាវ

ប្រធានបទ៖

# តួនាទី និងការទទួលខុសត្រូវរបស់មេធាវី ក្នុងរឿងក្តីរដ្ឋប្បវេណីនៅកម្ពុជា

# Role and Responsibility of Lawyer in Civil Case in Cambodia


ស្រាវជ្រាវដោយនិស្សិត៖ ជិន វណ្ណា

សាស្ត្រាចារ្យណែនាំ៖ បណ្ឌិត ព្រុំ ទេវី


ថ្នាក់បណ្ឌិត ជំនាន់ទី ៥ វគ្គ ១

ជំនាញ៖ នីតិសាស្ត្រ

ឆ្នាំ ២០២០

## ១.ចំណោទបញ្ហា

### ១.១. ចំណោទបញ្ហាសំខាន់

**តើមេធាវីមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះនៅក្នុងរឿងក្តីរដ្ឋប្បវេណីនៅកម្ពុជា**?

### ១.២. ចំណោទបញ្ហាបន្ទាប់បន្សំ

១. តើស្ថាប័នគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានតួនាទីអ្វីខ្លះ?

២. នៅក្នុងរឿងក្តីរដ្ឋប្បវេណីតើមេធាវីមានតួនាទីអ្វីខ្លះ?

៣. តើមេធាវីមានការទទួលខុសត្រូវអ្វីខ្លះនៅក្នុងរឿងក្តីរដ្ឋប្បវេណី?

៤. តើមេធាវីបាននឹងកំពុងចូលរួមចំណែកអ្វីខ្លះដើម្បីកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមតុលាការខេត្ត ក្រុង?

## ២- ឯកសារតម្រង់ទិស(គន្លងនិទ្ទេស)

១. ច្បាប់ស្តីលក្ខន្តិកៈមេធាវី, ២២.សីហា.១៩៩៥

២. ក្រមសីលធម៌មេធាវី, ២១.កញ្ញា.២០១២

៣. បទបញ្ជាផ្ទៃក្នុងគណៈមេធាវី, ១៥.វិច្ឆិកា.១៩៩៥

៤. ក្រមនីតិវិធីរដ្ឋប្បវេណី, ២០០៦

៥. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, ២០១០

៦. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, ២០១០

៧. ច្បាប់ស្តីពីនីតិវិធីនៃការពិន័យស៊ីវិល, ២០០៨

៨. សេចក្តីពន្យល់នៃក្រមនីតិវិធីរដ្ឋប្បវេណី, ២០១១

៩. ក្រមរដ្ឋប្បវេណី, ២០០៧

១០. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, ២០១១

១១. សេចក្តីពន្យល់នៃក្រមរដ្ឋប្បវេណី, ២០១១

១២. ច្បាប់ការងារ, ១៩៩៧

១៣. ច្បាប់ស្តីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, ១៩៩៩

១៤. ច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម, ២០០៥

១៥. ច្បាប់ភូមិបាល, ២០០១

១៦. ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

១៧. ក្រមព្រហ្មទណ្ឌ, ២០០៩

១៨. រដ្ឋធម្មនុញ្ញ, ១៩៩៣

១៩. ព្រះរាជក្រមលេខ ៦៤៨ នស″៣០.០៣.១៩៥១″ ស្តីពី វិជ្ជាជីវៈស្មាក្តី,ព.ស.២៤៩៤

២០. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ២០១៤

២១. ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, ២០១៤
២២. ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ២០១៤
២៣. លោក និក រីណេ, លោក លី អ៊ុយម៉េង៖ ការទទួលខុសត្រូវលើមុខវិជ្ជាជីវៈមេធាវី, មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍, ២០០០
២៤. លោក អាំង អេងថុង៖ វិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា,រាជធានីភ្នំពេញ ២០១០
២៥. ឯ.ឧ លី តៃសេង៖ មេធាវី និងសីលធម៌, ២០០៩
២៦. ឯ.ឧ សួន វិសាល៖ គោលការណ៍ដឹកនាំ និងគ្រប់គ្រងគណៈមេធាវី និងវិជ្ជាជីវៈមេធាវី, ២០១២
២៧. ឯ.ឧ ប៊ុន ហុន៖ វិជ្ជាជីវៈមេធាវីនៅក្នុងសង្គមកម្ពុជា, ២០១៦
២៨. អៀវ ប៊ុនរ៉េង៖ បច្ចេកទេសសវនាការនៃមេធាវីរដ្ឋប្បវេណី, ២០១១
២៩. អៀវ ប៊ុនរ៉េង៖ស្វ័យការពារសិទ្ធិ និងផលប្រយោជន៍នៃភាគីវិវាទក្នុងគ្រួសារ, ២០១១
៣០. ឯ.ឧ ហង់ ជួនណារ៉ុង៖ ទស្សនៈវិជ្ជា, ២០១៨
៣១. លោក សួន ឱសថ៖ ទ្រឹស្តីទស្សនវិជ្ជាច្បាប់, ពុទ្ធសាសនបណ្ឌិត្យ, ២០០៧
៣២. បណ្ឌិត ឈត ប៊ុនថង, ខ្មៅ សាវន, ប៉ាន់ វុត្ថា...៖ គ្រឹះរបស់ទស្សនៈវិជ្ជា, ២០០៨
៣៣. ប៉ាន់ វត្ថា៖ ទស្សនៈវិជ្ជា ភាពជាអ្នកដឹកនាំ និងភាពជាអ្នកគ្រប់គ្រង, រោងពុម្ព T.Y, ២០២០
៣៤. ប៉ា ចន្ទរឿន៖ ទស្សនវិជ្ជាថ្នាក់បញ្ចប់, គ្រឹះស្ថានបោះពុម្ពឯកសារខ្មែរ, ២០១៨
៣៥. បណ្ឌិត នេត ប៉ារ៉ុម៖ វិធីសាស្ត្រស្រាវជ្រាវ, ២០១៧
៣៦. បណ្ឌិត ព្រំ ទេវី៖ សាកល្បងរៀបចំគម្រោងស្រាវជ្រាវដោយខ្លួនឯង, ២០២០
៣៧. បណ្ឌិត ព្រំ ទេវី៖ វិធីសាស្ត្រសរសេរនិក្ខេបបទ, ២០២០
៣៨. បណ្ឌិត ឈុំ ភិតលន់៖ Statistics Analysis, 2020
៣៩. គណៈមេធាវី៖ ព្រឹត្តិបត្រមេធាវី "យុត្តិធម៌ និង ច្បាប់" លេខ ០១ ដល់លេខ ២៣ ឆ្នាំ ២០២០
៤០. គណៈមេធាវី៖ បញ្ជីលិខិតបទដ្ឋានមួយចំនួននៅកម្ពុជា១៩៩៣ -២០០៩, ២០០៩
៤១. គណៈមេធាវី៖ ទម្រង់រូបមន្តមេធាវី, ២០១១
៤២. គណៈមេធាវី៖ បញ្ជីសមាជិកមេធាវី, ២០១៩
៤៣. គណៈមេធាវី៖ របាយការណ៍ស្តីវឌ្ឍនភាពគណៈមេធាវី, ២០២០
៤៤. លោក គិន ភា៖វិធីសាស្ត្រសរសេរសារណា និងនិក្ខេបបទ,រាជបណ្ឌិត្យសភាកម្ពុជា ,២០២០

៤៥. លោក ហាប់ ផល្លី៖ វិធីសាស្រ្ត និងការសរសេរបែបសិក្សា, RULE, ២០១៩
៤៦. លោក សុខ ប៊ុនធឿន៖ប្រព័ន្ធច្បាប់ខ្មែរ, និក្ខេបបទបណ្ឌិតនីតិសាស្រ្ត, ២០១៤
៤៧. លោក សេង ប៊ុនធឿន៖ ការដោះស្រាយវិវាទពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា, និក្ខេបបទបណ្ឌិតនីតិសាស្រ្ត, ២០១២
៤៨. Mr.David Luban, The Good lawyer: Lawyer's roles and Lawyer's Ethics, 1983
៤៩. Mr. Mary Ann Glendon, A Nation under Lawyers, 1994.
៥០. Mr. Stephen Gillers, and Roy D.Simon Jr, Regulations of Lawyers, 1997
៥១. "Les Regles de la profession d'avocat", Collection Dalloz-Edition 1995.
៥២. Mr. Donal R. Cooper, Pamela S. Schindler, Business Research Methods, 12th Edition, 2012
៥៣. Mr. Bassham, Mr. Irwin, Mr. Nardone, Mr. Wallace, Critical Thinking, 4th Edition,
៥៤. Mr. Theodore Schick.Jrç Lewis Vaughn, How to Think about Weird Things, 7th Edition, 2014
៥៥. www.bakc.org.kh

## ៣. គោលដៅនៃការសិក្សាស្រាវជ្រាវ

១. ការសិក្សាស្ថានភាពទូទៅនៃស្ថាប័នគណៈមេធាវីនាពេលបច្ចុប្បន្ន
២. សិក្សាស្រាវជ្រាវពីតួនាទី និងការទទួលខុសត្រូវរបស់មេធាវីនៅក្នុងរឿងក្តីរដ្ឋប្បវេណីនានាដូចជា៖ រឿងក្តីវិវាទពាណិជ្ជកម្ម, វិវាទដីធ្លី, វិវាទការងារ, វិវាទកិច្ចសន្យា, ការបែងចែកមរតក, ករណីលែងលះ, ការចុះបញ្ជីក្រុមហ៊ុន ជាដើម។
៣. សារៈសំខាន់របស់មេធាវីក្នុងចូលរួមចំណែកកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមតុលាការខេត្ត ក្រុង និងទស្សនៈវិស័យទៅអនាគត។

## ៤. អថេរនៃការសិក្សាស្រាវជ្រាវ

### ៤.១. អថេរ (ទី១)

#### ១. អថេរឯករាជ្យ

- តួនាទី និងការទទួលខុសត្រូវរបស់មេធាវីនៅក្នុងរឿងក្តីរដ្ឋប្បវេណីនៅកម្ពុជា។

#### ២. អថេរមិនឯករាជ្យ

- ការកើនឡើងនៃសំណុំរឿងក្តីនៅតាមតុលាការរាជធានី ខេត្ត ដែលក្នុងនោះមេធាវីដើរតួយ៉ាងសំខាន់ក្នុងការចូលរួមជួយការពារសិទ្ធិ និងតំណាងដោយអាណត្តិជូនកូនក្តី។

#### ៣. អថេរខាងក្រៅ

- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

**៤. អថេរអន្តរាគមន៍**

- គោលនយោបាយរបស់រាជរដ្ឋាភិបាល កាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមបណ្តាតុលាការរាជធានី ខេត្ត។

### ៤.២. អថេរ (ទី២)

**១. អថេរឯករាជ្យ**

- តួនាទី និងការទទួលខុសត្រូវរបស់មេធាវីនៅក្នុងរឿងក្តីរដ្ឋប្បវេណីនៅកម្ពុជា។

**២. អថេរមិនឯករាជ្យ**

- ប្រជាពលរដ្ឋមានការយល់ដឹងពីការប្រើប្រាស់សេវាមេធាវីនៅមានកម្រិត។ ពួកគេបាននឹងកំពុងជួបបញ្ហាជម្លោះ និងវិវាទកើនឡើងច្រើន។

**៣. អថេរខាងក្រៅ**

- បង្កើនកិច្ចសហការរវាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នតុលាការគ្រប់ជាន់ថ្នាក់ និងសហការជាមួយគណៈមេធាវីបរទេសនានា។

**៤. អថេរអន្តរាគមន៍**

- ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ សែន ជួយការពារក្តីជូនស្ត្រីក្រីក្រទូទាំងប្រទេស។

### ៤.៣. អថេរ (ទី៣)

**១. អថេរឯករាជ្យ**

- តួនាទី និង ការទទួលខុសត្រូវរបស់មេធាវីនៅក្នុងរឿងក្តីរដ្ឋប្បវេណីនៅកម្ពុជា។

**២. អថេរមិនឯករាជ្យ**

- ស្ថានភាពទូទៅនៃស្ថាប័នគណៈមេធាវី និងការខ្វះមេធាវីសម្រាប់ការពាសិទ្ធិ និងតំណាងដោយអាណត្តិជូនកូនក្តីនាពេលបច្ចុប្បន្ន។

**៣. អថេរខាងក្រៅ**

- បង្កើនចំនួនសមាជិកមេធាវីដើម្បីឆ្លើយតបទៅតាមតម្រូវការទីផ្សារបច្ចុប្បន្ន។

**៤. អថេរអន្តរាគមន៍**

- ក្រុមមេធាវីស្ម័គ្រចិត្តរបស់ក្រសួងយុត្តិធម៌ ដើម្បីជួយការពារ និងតំណាងដោយអាណត្តិដល់ជនក្រីក្រតាមរាជធានី ខេត្ត។

## ៥. សម្មតិកម្ម

- សារៈសំខាន់នៃការប្រើសេវាមេធាវីដើម្បីជួយតាក់តែងឯកសារគតិយុត្តនានា
- ភារកិច្ចរបស់មេធាវីក្នុងការតំណាងដោយអាណត្តិឱ្យកូនក្តីរបស់ខ្លួនក្នុងសំណុំរឿងរដ្ឋប្បវេណី

- ការទទួលខុសត្រូវរបស់មេធាវីក្នុងការតំណាងដោយអាណត្តិឱ្យកូនក្ដីរបស់ខ្លួនក្នុងសំណុំរឿងរដ្ឋប្បវេណី
- ការចូលរួមផ្ដល់សេវាកម្មផ្នែកច្បាប់ដល់អតិថិជន និងការកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមតុលាការរាជធានី ខេត្ត។
- ការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយអំពីសេវាកម្មមេធាវីទៅសាធារណៈជន
- វិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវីឆ្នាំ ១៩៩៥ និងបន្ថែមនូវគោលការណ៍ច្បាប់ថ្មីដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន។
- សមាជិកមេធាវីគ្រប់រូបត្រូវប្រកាន់ភ្ជាប់នូវមនសិការវិជ្ជាជីវៈមេធាវី និង ក្រមសីលធម៌មេធាវី។

## ៦- ពេលវេលានៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ ត្រូវពេលរយៈពេល ៧ សប្ដាហ៍ ដោយចាប់គិតពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដល់ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២១។

សប្ដាហ៍ទី១៖ ត្រូវសម្ភាសប្រជាពលរដ្ឋឱ្យបាន ចំនួន ២០ នាក់។

សប្ដាហ៍ទី២៖ ត្រូវសម្ភាសប្រជាពលរដ្ឋឱ្យបាន ចំនួន ២០ នាក់។

សប្ដាហ៍ទី៣៖ ត្រូវសម្ភាសប្រជាពលរដ្ឋឱ្យបាន ចំនួន ២០ នាក់។

សប្ដាហ៍ទី៤៖ ត្រូវសម្ភាសប្រជាពលរដ្ឋឱ្យបាន ចំនួន ២០ នាក់។

សប្ដាហ៍ទី៥៖ ត្រូវសម្ភាសប្រជាពលរដ្ឋឱ្យបាន ចំនួន ២០ នាក់។

សប្ដាហ៍ទី៦៖ ប្រមូលនិងដកស្រង់ ឯកសារពាក់ព័ន្ធសំខាន់ៗ និងចាប់ផ្ដើមវាយអត្ថបទ។

សប្ដាហ៍ទី៧៖ ផ្ទៀងផ្ទាត់ទម្រង់ និងខ្លឹមសារនៃអត្ថបទ រួចប្រគល់កិច្ចការជូនលោកសាស្ត្រាចារ្យ។

## ៧- តំបន់ទិសដៅ

កិច្ចការស្រាវជ្រាវនេះ បានកើតឡើងតាមរយៈ៖

- ការសិក្សាស្រាវជ្រាវតាមបណ្ណាល័យរាជបណ្ឌិតសភាកម្ពុជា បណ្ណសារដ្ឋានជាតិ បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បណ្ណាល័យគណៈមេធាវី និងបណ្ណាគារផ្សេងៗ
- ការស្រាវជ្រាវតាមវេបសាយនានាពាក់ព័ន្ធនឹងមេធាវី
- តាមរយៈនិក្ខេបបទរបស់រៀមច្បងជំនាន់មុនៗ
- ការសិក្សាស្រាវជ្រាវឯកសារផ្ដល់ជូនដោយសាស្ត្រាចារ្យបណ្ឌិត ព្រុំ ទេវី
- ការសិក្សាស្រាវជ្រាវឯកសារច្បាប់នានាពាក់ព័ន្ធមេធាវី

- តាមរយៈការពន្យល់ពីមិត្តរួមថ្នាក់ និងរៀមច្បងដែលមានចំណេះដឹង និងបទពិសោធន៍

- តាមរយៈការពន្យល់ណែនាំរបស់សាស្ត្រាចារ្យបណ្ឌិតរាជបណ្ឌិត្យសភាកម្ពុជា

- តាមរយៈការពន្យល់ណែនាំរបស់សាស្ត្រាចារ្យបណ្ឌិត ព្រំ ទេវី ទទួលបន្ទុកមុខវិជ្ជាការស្រាវជ្រាវសម្រាប់និក្ខេបទ។

- តាមរយៈការអនុវត្តជាក់ស្តែងក្នុងប្រព័ន្ធតុលាការក្នុងនាមជាមេធាវីប្រកបវិជ្ជាជីវៈ និងតាមរយៈកត្តាផ្សេងៗទៀត

- ការចុះទៅសម្ភាសផ្ទាល់ជាមួយប្រជាពលរដ្ឋនៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

## ៨-ក្រុមគោលដៅ

-រាជរដ្ឋាភិបាលបានណែនាំដល់ប្រធានគណៈមេធាវី ធ្វើយ៉ាងណាពង្រាយសមាជិកមេធាវីទៅតាមបណ្តាគ្រប់ខេត្តក្រុង ដើម្បីឱ្យប្រជាពលរដ្ឋមានលទ្ធភាពស្វែងរកអ្នកច្បាប់ដើម្បីប្រឹក្សាយោបល់ផ្នែកច្បាប់ ឬមេធាវីការពារសិទ្ធិ ឬអ្នកតំណាងឱ្យពួកគេ។

-ប្រធានគណៈមេធាវីបានអនុវត្តតាមគោលការណ៍ណែនាំរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានពង្រាយសមាជិកមេធាវីគ្រប់បណ្តាខេត្តក្រុងប្រចាំការយ៉ាងតិច ០១ នាក់។

- ប្រជាពលរដ្ឋទទួលបានការប្រឹក្សាយោបល់ផ្នែកច្បាប់ និងទទួលបានសេវាមេធាវីដើម្បីដោះស្រាយបញ្ហារបស់ពួកគេ ទទួលបានផលគួរឱ្យកត់សម្គាល់។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយចំនួនសមាជិកមេធាវីក៏ពុំទាន់គ្រប់គ្រាន់សមាមាត្រនឹងចំនួនប្រជាពលរដ្ឋនៅឡើយ។

- គណៈមេធាវីចាំបាច់ត្រូវជ្រើសរើសសមាជិកមេធាវីបន្ថែមស្របតាមមាត្រា ៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

## ៩-ឧបករណ៍ស្រាវជ្រាវ

### ៩.១. ការរៀបចំកម្រងសំណួរ

- ចុះទៅសម្ភាសន៍ជាមួយប្រជាពលរដ្ឋដោយផ្ទាល់ចំនួន ១០០ នាក់ (អាយុចាប់ពី ១៨ ឆ្នាំរហូតដល់អាយុ ៧០ ឆ្នាំ) នៅខណ្ឌ ឬស្សីកែវ  រាជធានីភ្នំពេញ ហើយយើងទទួលបានលទ្ធផលដូចខាងក្រោម៖

- តាមរយៈរូបមន្តរបស់លោក Yamane (1969) បានកំណត់ពីរបៀបគណនាសំណាក ៖

$$N = \frac{N}{1 + Ne2}$$

- ធ្វើសេចក្តីសន្និដ្ឋានពីទិន្នន័យដែលយើងទទួលបាន

### ៩.២. វិធីសាស្ត្រប្រមូលទិន្នន័យ

វិធីសាស្ត្រនៃការប្រមូលទិន្នន័យមានចំនួន ៤ ប្រភេទ ដូចតទៅ៖

១- ភេទ៖ ប្រុស ឬ ស្រី

២- អាយុ៖ ចាប់ពី ១៨ ឆ្នាំ ដល់ ៧០ ឆ្នាំ

៣- វិវាទពាក់ព័ន្ធនឹងរឿងក្តីរដ្ឋប្បវេណី

៤- ការប្រើសេវាមេធាវីនៅក្នុងរឿងក្តីរដ្ឋប្បវេណី

## ១០-វិធីសាស្ត្រសិក្សាទិន្នន័យ

-ការវិភាគទិន្នន័យ គឺយើងបានចុះទៅសម្ភាសដោយផ្ទាល់ជាមួយប្រជាពលរដ្ឋនៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ដើម្បីប្រមូលព័ត៌មានឱ្យកាន់តែច្បាស់លាស់ និងជាក់លាក់ ចំពោះប្រជាពលរដ្ឋដែលធ្លាប់មាន ឬកំពុងកើតមានវិវាទរឿងក្តីរដ្ឋប្បវេណីជាក់ស្តែង និងបាននឹងកំពុងប្រើប្រាស់សេវាមេធាវី។

-យើងបានវិភាគទិន្នន័យតាមរូបមន្តលោក Yamane និងធ្វើការវិភាគទិន្នន័យ Secondary Data ផ្អែកលើការគណនាគណិតវិទ្យា ស្ថិតិ និងប្រូបាបប៊ីលីតេ តាមរយៈប្រព័ន្ធ SPSS និង Excell ជាជំនួយក្នុងការតម្លើងក្រាបសរសេរ ដើម្បីបង្ហាញឱ្យកាន់តែច្បាស់លាស់ថែមទៀត។

-បន្ទាប់មកទៀត យើងនឹងបង្ហាញពីលទ្ធផល និងធ្វើការបកស្រាយពីទិន្នន័យដែលយើងប្រមូលបាន។

-ការពិភាក្សាលើលទ្ធផល

-ធ្វើសេចក្តីសន្និដ្ឋាន។